# បច្ចេកទេសចិញ្ចឹមមាន់ស្រុកសម្រាប់ទីផ្សារ

## ការរៀបចំ និងសាងសង់ទ្រុងសម្រាប់មាន់

### តើយើងធ្វើទ្រុងថែរក្សាកូនមាន់យ៉ាងដូចម្តេច?









### ការសាងសង់ទ្រុងមាន់ធំ (ពិនិត្យកាត់មើលពីលើ)

















- ចំនួនសំបុកត្រូវសមស្របតាមចំនួនមេមាន់
- កុំឲ្យមានស្រមើរត្រូវដាក់បាតសំបុក៖ ថ្នាំជក់ ស្លឹកចេក ស្លឹកសាវម៉ាវព្រៃ ស្លឹកស្តៅ ស្លឹកគ្រៃ ស្លឹកទាប ឬស្លឹកទន្ទ្រានខែត្រ

### ស្នូកចំណីមាន់







**គុណសម្បត្តិស្នូកចំណីធ្វើពីធុងជ័រ៖**

- មិនធ្វើឲ្យចំណីកំពប់ ខ្ជះខ្ជាយដោយការចឹកចំណីចោល និងមិនឲ្យកកាយ
- ចំណាយលុយតិចសម្រាប់ទិញ ឬធ្វើ
- អនាម័យល្អ

### ស្នូកទឹកមាន់






# ការជ្រើសរើសពូជមាន់ និងការគ្រប់គ្រងកូនមាន់

## តើត្រូវជ្រើសរើសមាន់សម្រាប់ចិញ្ចឹមរបៀបណា?



- កូនមាន់មានចលនាក្លៀវក្លា រហ័សរហួន
- មេបាសុខភាពល្អ និងមិនធ្លាប់កើតជម្ងឺធ្ងន់
- មិនត្រូវទិញកូនមាន់មានរោមស្អិត ពោះធ្លាក់ ឬរឹង និងមានព៌ណខៀវ



- មានរាងល្អ ធំជាត់ រឹងមាំ មិនធ្លាប់កើតជម្ងឺធ្ងន់
- មានទម្ងន់ពី ២គ.ក្រ ឡើង
- រហ័សរហួន ពូកែជាន់មេ
- មានអាយុពី ៩ខែ ទៅ ៣ឆ្នាំ

- រូបរាងធំជាត់ រឹងមាំ និងមិនដែលកើតជម្ងឺធ្ងន់
- មានទម្ងន់ពី ១,២គ.ក្រ ឡើង
- អាយុពី ៧ខែ ទៅ ៣ឆ្នាំ



- មេផ្តល់ស៊ុត ១ឆ្នាំ បាន ៤ ទៅ ៥សារ
- ពង ១សារៗ មានស៊ុតពី ៨ ទៅ ១២គ្រាប់
- កូនញាស់យ៉ាងតិច ៨ក្បាល ក្នុង ១សំបុក

### វដ្តជីវិតមាន់




## តើយើងបំបែកកូនមាន់ពីមេនៅអាយុ ១០ថ្ងៃយ៉ាងដូចម្តេច?

ដាក់មេ និងកូនទើបញាស់ក្នុងទ្រុងកូនដែលមានក្រាលអង្កាម ឬកំទេចអាចម៍រណា



- យកមេចេញពេលកូនមាន់អាយុ១០ថ្ងៃ
- ត្រូវយកបាវ ឬក្រដាសបាំងជុំវិញទ្រុងកូនមាន់ដើម្បីរក្សាកំដៅកូនមាន់



បើត្រជាក់ខ្លាំង ឬពេលយប់ត្រូវបន្ថែមកំដៅ ដោយប្រើក្អមធ្យូងកំដៅ ឬអំពូលភ្លើង (មូល)



កូនមាន់អាយុបាន ១ខែ ព្រលែងឲ្យដើរស៊ីចំណីដោយសេរីនៅក្នុងទ្រុងបំប៉ន



## តើយើងអាចដឹងពីកំដៅក្នុងទ្រុងកូនមាន់យ៉ាងដូចម្តេច?




កំដៅល្មមគ្រប់គ្រាន់ | កំដៅខ្លាំងពេក (នៅឆ្ងាយពីប្រភពកំដៅ) | កំដៅត្រជាក់ខ្លាំង




កំដៅសម្រាប់មាន់ ៣៥-៣៧អង្សាសេ

# ចំណីអាហារសម្រាប់មាន់

## តើចំណីមាន់ផ្សំពីអ្វីខ្លះដើម្បីឲ្យមានគុណភាពល្អ និងមាន់លូតលាស់លឿន?




## តើសារធាតុចំណីទាំងនេះមានប្រភពមកពីណា?

### ប្រូតេអ៊ីន




### ថាមពល




### វីតាមីន




### សារធាតុរ៉ែ

សំបកខ្ចង ខ្ចៅ លៀស គ្រំ...



# ការផ្តល់ចំណីអាហារសម្រាប់មាន់

## តើត្រូវផ្តល់ចំណីមាន់អាយុចាប់ពី១ខែឡើងយ៉ាងដូចម្តេច?




៥០%




៥០%



ច្របល់ចំណីចូលគ្នា







ផ្តល់បន្លែបន្ថែម សម្រាប់មាន់ ដោយព្យួរក្នុងទ្រុង

## ការផ្តល់ចំណីកូនមាន់



- អាយុ ១ថ្ងៃ ទៅ ១៤ថ្ងៃ ផ្តល់ចំណីផ្សំស្រេចសុទ្ធ (បាវ)
- អាយុ ១៥ ទៅ ២១ថ្ងៃ ផ្តល់ចំណីផ្សំស្រេច ដោយលាយចុងអង្ករ និងកន្ទក់ ២០%
- អាយុ ២២ ទៅ ៣០ថ្ងៃ ផ្តល់ចំណីផ្សំស្រេច ដោយលាយចុងអង្ករ កន្ទក់ និងបន្លែ៣០%
- ផ្តល់ទឹកឲ្យគ្រប់គ្រាន់ចាប់ពីញាស់

# ជីវៈសុវត្ថិភាព និងអនាម័យមាន់

បាចទឹកកំបោរសម្លាប់មេរោគ ក្នុងទ្រុងបាន១អាទិត្យ ទើបដាក់មាន់ចិញ្ចឹម



- ដាក់មាន់ជាក្រុមតាមអាយុ
- ផ្ទៃបាតទ្រុងស្ងួតជានិច្ច
- បាតទ្រុងត្រូវដាក់អង្កាម
- សំអាតលាមករៀងរាល់ថ្ងៃ
- សំអាតស្នូកចំណីរាល់ថ្ងៃ
- ផ្លាស់ប្តូរទឹកឲ្យបានញឹកញាប់





ដាក់ទឹកកំបោរនៅមាត់ទ្វារសម្រាប់ជ្រលក់បាតជើងសម្លាប់មេរោគមុនចូល

មាន់មកថ្មីត្រូវក្រុងទុក ២អាទិត្យ បើឃើញមានសុខភាពល្អទើបដាក់ចូលគ្នា (ការពារឆ្លងជម្ងឺ)



មិនត្រូវឲ្យឈ្មួញទិញមាន់ និងអ្នកដ៏ទៃចូលក្នុងទ្រុងមាន់ ឬក្នុងទីធ្លាចិញ្ចឹមមាន់



បើមាន់ងាប់ដោយជម្ងឺត្រូវយកទៅកប់ ឬដុតចោល





## ការការពារជម្ងឺ និងទម្លាក់ព្រូនមាន់

### ជម្ងឺឆ្លងសំខាន់ៗបណ្តាលឲ្យមាន់ឈឺ និងងាប់



ជម្ងឺញ៉ូវកាស ឬ ដង្កោកាច់



ជម្ងឺអុតមាន់ (ដុំពកលើក្បាល មុខ)



ជម្ងឺអាសន្នរោគ

### តើត្រូវការពារមាន់កុំឲ្យកើតជម្ងឺទាំងនេះយ៉ាងដូចម្តេច?

- ចាក់វ៉ាក់សាំងការពារ មុនពេលសត្វឈឺ
- ចាក់វ៉ាក់សាំងការពារជម្ងឺមាន់ទាំងអស់ឲ្យបានយ៉ាងតិច៣មុខ ទៅតាមអាយុរបស់មាន់ (ជម្ងឺញ៉ូវកាស, អុត និងអាសន្នរោគ)
- ចាក់រំលឹកឡើងវិញឲ្យបានទៀងទាត់ ជាពិសេសមេបាពូជ
- វ៉ាក់សាំងដែលនៅសល់ពីការប្រើប្រាស់ត្រូវដុត ឬកប់ចោល

### កម្មវិធីចាក់វ៉ាក់សាំង និងទំលាក់ព្រូន

អាយុ ១ ទៅ ៣ ថ្ងៃ



បន្តក់វ៉ាក់សាំងញ៉ូវកាសនៅភ្នែក ច្រមុះ

អាយុ៧ ទៅ ១០ថ្ងៃ



ជួសស្លាបរង់វ៉ាក់សាំងអុត



អាយុ២ខែ



ចាក់វ៉ាក់សាំងអាសន្នរោគនៅសាច់ដុំទ្រូង

អាយុ ២ខែកន្លះ



ទម្លាក់ព្រូន